សេចក្តីព្រាង

# បទអន្តរាគមន៍
## ស្តីពីភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំ (២០១៨-២០២២) របស់រដ្ឋបាលខេត្តកំពង់ស្ពឺ
## ដោយឯកឧត្តម វ៉ី សំណាង អភិបាល នៃគណៈអភិបាលខេត្តកំពង់ស្ពឺ

ទីស្តីការគណៈរដ្ឋមន្ត្រី ថ្ងៃទី ៩ ខែ កុម្ភៈ ឆ្នាំ២០២៣

- **អរគុណសន្តិភាព អរគុណនយោបាយឈ្នះ ឈ្នះ គោរពដឹងគុណ ស្ថាបនិកមគ្គុទេសក៍ឯកប្រតិបត្តិករនយោបាយ ឈ្នះ ឈ្នះ ដែលបាននាំមកនូវសុខសន្តិភាព ការឯកភាពជាតិពេញលេញ !**

**ជាបឋម ៖**

ខ្ញុំបាទសូមគោរព **សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី** ដែលបានទស្សនាការផ្សាយបន្តផ្ទាល់ និងឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលមានវត្តមាននៅក្នុងសាលសន្និសីទសារព័ត៌មាន នាឱកាសនេះជាទីគោរព និង ជាទីរាប់អាន !

ថ្ងៃនេះខ្ញុំពិតជាមានកិត្តិយស និងសេចក្តីសោមនស្សរីករាយក្រៃលែង ក្នុងនាមរដ្ឋបាលខេត្តកំពង់ស្ពឺ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ដែលបានមកចូលរួមក្នុងសន្និសីទសារព័ត៌មាននាថ្ងៃនេះ។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះអង្គភាពអ្នកនាំពាក្យរាជរដ្ឋាភិបាល ដែលបានរៀបចំនូវសន្និសីទសារព័ត៌មានស្តីពី "**ភាពជោគជ័យក្នុងរយៈពេល ៥ឆ្នាំ(២០១៨-២០២២) របស់រដ្ឋបាលខេត្តកំពង់ស្ពឺ**" នាពេលនេះ និងសូមអរគុណចំពោះវត្តមាន ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី និងបងប្អូនអ្នកសារព័ត៌មានទាំងអស់ ដែលមានវត្តមាននៅទីនេះ។

ឆ្លៀតក្នុងឱកាសនេះផងដែរ ខ្ញុំសូមសម្តែងនូវការដឹងគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានដាក់ចេញនូវចក្ខុវិស័យ និងគោលនយោបាយដ៏ត្រឹមត្រូវរក្សាបាននូវសន្តិភាព ស្ថិរភាពនយោបាយ ជាពិសេសរក្សាបាននូវកំណើនសេដ្ឋកិច្ច ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋនៅទូទាំងប្រទេសបានជាបន្តបន្ទាប់ ដែលនឹងឈានទៅប្រែក្លាយប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសដែលមានចំណូលកម្រិតខ្ពស់នៅឆ្នាំ២០៥០។

នៅក្នុងបរិបទឧស្សាហកម្ម៤.0 បាននឹងកំពុងរីកចម្រើនលើផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសាកលមានការវិវឌ្ឍយ៉ាងឆាប់រហ័ស។ បច្ចេកវិទ្យាឌីជីថលបាននឹងកំពុងដើរតួនាទីជាស្នូល និងជាចលករនៅក្នុងគ្រប់ទិដ្ឋភាពនៃសកម្មភាពសេដ្ឋកិច្ច និងសង្គមដែលមានភាពសម្បូរបែប និងផលិតភាពនៃប្រតិបត្តិការការងារប្រចាំថ្ងៃរបស់យើង។ មិនត្រឹមតែប៉ុណ្ណោះ តាមរយៈការដាក់ចេញនូវគោលនយោបាយ **ឈ្នះ-ឈ្នះ របស់សម្តេចតេជោ** បានធ្វើឱ្យប្រទេសជាតិមានសុខសន្តិភាពពេញផ្ទៃប្រទេសមិនធ្លាប់មានក្នុងរយៈពេលជាង ៥០០ឆ្នាំមកហើយ

ប្រជាជនទូទាំងប្រទេសទទួលបាននូវសិទ្ធិសេរីភាពពេញបរិបូណ៌។ ជាមួយនឹងសមិទ្ធផលដែលរាជរដ្ឋាភិបាលសម្រេចបានកន្លងមកនេះ រដ្ឋបាលខេត្តកំពង់ស្ពឺក៏បានទទួលនូវផ្លែផ្កាយ៉ាងច្រើនផងដែរ ដោយបានប្រែក្លាយទឹកដីខេត្តកំពង់ស្ពឺពីការប្រឈមមុខដាក់គ្នាដោយចុងអាវុធ មកជាខេត្តប្រកបដោយសក្តានុពល ជាតំបន់សេដ្ឋកិច្ចដែលមានរោងចក្រសហគ្រាសធំៗកំពុងធ្វើអាជីវកម្ម និងបន្ត មកបណ្តាក់ទុនវិនិយោគជាបន្តបន្ទាប់។

- **សម្តេច ឯកឧត្តម លោកជំទាវជាទីគោរព!**
- **ភ្ញៀវកិត្តិយស បងប្អូនអ្នកសារព័ត៌មានជាទីគោរពរាប់អាន!**

ជាបន្តទៅនេះ ខ្ញុំសូមអនុញ្ញាតគោរពរាយការណ៍ជូនដល់អង្គសន្និសីទមេត្តាជ្រាបថា រយៈពេល ៥ឆ្នាំកន្លងមកនេះ ដោយអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព និងមានការចូលរួមសហការពីអាជ្ញាធរគ្រប់លំដាប់ថ្នាក់ អង្គភាពពាក់ព័ន្ធ និងពីគ្រប់មជ្ឈដ្ឋាន ប្រជាពលរដ្ឋក្នុងខេត្តយើងទទួលបានការរីកចម្រើននូវគ្រប់វិស័យ ព្រមទាំងទទួលបាននូវសន្តិសុខ សណ្តាប់ធ្នាប់ សុវត្ថិភាពសង្គមបានល្អប្រសើរ។

**ខេត្តកំពង់ស្ពឺ** ដីមានសណ្ឋានខ្ពង់រាប ស្ថិតនៅផ្នែកនិរតីនៃប្រទេសកម្ពុជា ចន្លោះប៉ូល សេដ្ឋកិច្ចធំពីរ គឺ រាជធានីភ្នំពេញ និង ខេត្តព្រះសីហនុ។ ព្រំប្រទល់ខាងលិចជាប់ខេត្តកោះកុង និងខេត្តព្រះសីហនុ ខាងកើតជាប់ខេត្តកណ្តាល និងខេត្តតាកែវ ខាងជើងជាប់ខេត្តកំពង់ឆ្នាំង និងខេត្តពោធិ៍សាត់ ខាងត្បូងជាប់ ខេត្តតាកែវ និងខេត្តកំពត។

## ១-ការគ្រប់គ្រងរដ្ឋបាល

ខេត្តកំពង់ស្ពឺចែកជា ១ក្រុង និង ៧ស្រុក សង្កាត់ចំនួន៥ ឃុំចំនួន៨៣ ភូមិចំនួន១.៣៧៩ភូមិ។ យោងតាមអនុក្រឹត្យ លេខ ២៧១ អនក្រ ចុះថ្ងៃទី ២៣ ខែធ្នូ ឆ្នាំ២០២២ ត្រូវបានបែងចែកតំបន់រដ្ឋបាល នៃស្រុកឧដុង្គជាពីរ គឺក្រុងឧដុង្គម៉ែជ័យ និង ស្រុកសាមគ្គីមុនីជ័យ ប៉ុន្តែដោយបច្ចុប្បន្នកំពុងរៀបចំរចនាសម្ព័ន្ធរដ្ឋបាលក្រុង និងស្រុកមិនទាន់បានដាក់ឱ្យដំណើរការនៅឡើយ។

ផ្ទៃដីទូទាំងខេត្តសរុបមានចំនួន ៦.៩៦៥,៦៣គ.ម$^{២}$ គ្រួសារសរុប ២២២.២៥៧គ្រួសារ ប្រជាជនសរុប ៨៧០.០៨១/៩១៧.២៧៧នាក់ ធៀបឆ្នាំ២០១៨ កើនឡើង ៤៧.១៩៦នាក់ ភាគច្រើនជាប្រជាជនចំណាកស្រុកមកពីបណ្តាខេត្តនានា។

បច្ចុប្បន្នលំនៅដ្ឋានប្រជាពលរដ្ឋប្រកស្លឹកស្បូវចំនួន ៩៨១ខ្នង, ផ្ទះប្រកហ្វីប្រូស៊ីម៉ង់ ៧៤.១៦៧ខ្នង, ផ្ទះប្រកសង្កសី ៥.៦២៦ខ្នង, ផ្ទះប្រកក្បឿង ១១០.១៦២ខ្នង, ផ្ទះថ្មមិនមែនបេតុង ១៤.៥២៩ខ្នង, ផ្ទះល្វែង ៣.៧៩១ខ្នង និងភូមិគ្រឹះ (វីឡា) ២០៨ខ្នង។

ប្រាក់ចំណូល ជាមធ្យមប្រចាំឆ្នាំរបស់ប្រជាជនប្រមាណ ១.៦៩៣ ដុល្លារអាមេរិក។

តាមរយៈកម្មវិធីកំណែទម្រង់វិជ្ឈការនិងវិសហមជ្ឈការ រដ្ឋបាលក្រុង ស្រុកទាំងអស់ក្នុងខេត្តកំពង់ស្ពឺបានទទួលការធ្វើសមាហរណកម្មការិយាល័យជំនាញនានាជុំវិញក្រុង ស្រុក ទៅក្នុងរចនាសម្ព័ន្ធថ្មី ដែលមានមន្ត្រីសរុប ៧៥០នាក់/ស្រី ១៨៧នាក់ (មុនធ្វើសមាហរណកម្មមានចំនួន ៣៨៦នាក់/ស្រី១២១នាក់)។ មិនត្រឹមតែប៉ុណ្ណោះ រដ្ឋបាលខេត្ត និងក្រុង ស្រុកក៏ទទួលបានការធ្វើប្រតិភូកម្មអំណាចពីវិស័យមួយចំនួនក្នុងការផ្តល់សេវារដ្ឋបាលតាមរយៈអង្គភាពច្រកចេញចូលតែមួយរដ្ឋបាលខេត្ត និងការិយាល័យច្រកចេញ

ចូលតែមួយរដ្ឋបាលក្រុង ស្រុក ដែលមាននៅគ្រប់ទាំង ៨ ក្រុង ស្រុក ទន្ទឹមនេះក៏មានយន្តការច្រកចេញចូលតែមួយនៅគ្រប់បណ្តាឃុំ សង្កាត់ផងដែរ ដែលទើបដាក់ឱ្យដំណើរការនាចុងឆ្នាំ២០២២ កន្លងមកនេះ។

ក្នុងរយៈពេល៥ឆ្នាំ (២០១៨-២០២២) ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋតាមរយៈយន្តការច្រកចេញចូលតែមួយរបស់រដ្ឋបាលខេត្តសរុបចំនួន ១២៨.១២៧សេវា/ស្រី ៥១.៩៧៦នាក់ និងទទួលបានចំណូលសរុប ២១.៧២៤.៦៨៣.៤០០រៀល (**ម្ភៃមួយប៊ីលាន ប្រាំពីររយម្ភៃបួនលាន ប្រាំមួយរយប៉ែតសិបបីពាន់បួនរយរៀលគត់**) ក្នុងនោះរួមមាន ៖ (ការងារនីត្យានុកូលកម្មចំនួន ១.៣១០សេវា, ការងាររដ្ឋបាលចំនួន ២៦២សេវា, វិស័យសុខាភិបាលចំនួន ២៣៨សេវា, វិស័យទេសចរណ៍ចំនួន ១០៥សេវា, វិស័យសាធារណៈការ និងដឹកជញ្ជូនចំនួន ៤.០៨៨សេវា, វិស័យព័ត៌មានចំនួន ៤៤៨សេវា, វិស័យបរិស្ថានចំនួន ១០៣សេវា, វិស័យឧស្សាហកម្ម បច្ចេកវិទ្យា វិទ្យាសាស្ត្រ និងនវានុវត្តន៍ចំនួន ៨២៥សេវា, វិស័យរ៉ែ និងថាមពលចំនួន៤០៩សេវា, វិស័យពាណិជ្ជកម្មចំនួន ៩៥សេវា, វិស័យរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ចំនួន ៣៨.៧៩៥សេវា, វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទចំនួន ៦.៣៧៩សេវា និងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ៧៥.០៧០សេវា )។

ការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋ ការិយាល័យច្រកចេញចូលតែមួយនៅរដ្ឋបាលក្រុង និងស្រុក សរុបចំនួន ២៩៤.២១៣សេវា ស្រី ១០៣.៧៨៥នាក់ ទទួលបានចំណូលសរុប ២.៥៩៧.៦២៧.១០០រៀល ។ បច្ចុប្បន្ន ដើម្បីផ្តល់ភាពងាយស្រួលដល់ប្រជាពលរដ្ឋឱ្យបានកាន់តែមានប្រសិទ្ធភាពយន្តការច្រកចេញចូលតែមួយ រដ្ឋបាល ឃុំ សង្កាត់ ទូទាំងខេត្ត ក៏ត្រូវបានដាក់ឱ្យដំណើរការផ្តល់ សេវា ជូនប្រជាពលរដ្ឋផងដែរ ចាប់ពីខែតុលា ចុងឆ្នាំ២០២២កន្លងមកនេះ។

គម្រោងវិនិយោគអភិវឌ្ឍន៍ខេត្តសរុប ៣៦គម្រោងត្រូវបានអនុវត្ត ចំណាយថវិកាសរុបចំនួន ៤០.៧៦៥.១០០.០០០រៀល គម្រោងក្រុង ស្រុកចំនួន ៦៨គម្រោង ចំណាយថវិកាសរុបចំនួន ៤,៩៩៥,៦៦៣,២០០រៀល និងគម្រោងអភិវឌ្ឍន៍ឃុំ សង្កាត់ បានចំនួន ៤៤៨គម្រោង ចំណាយថវិកាសរុប ៧៧,៧៣៩,៩៨៤,២៨៣រៀល។

បច្ចុប្បន្ននៅទូទាំងខេត្តមានស្ថានីយ៍ផលិតនិងផ្គត់ផ្គង់ទឹកស្អាតឯកជនសរុបចំនួន ៥២ មូលដ្ឋាន ប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់ចំនួន ៩១.៨២៦គ្រួសារ ស្មើនឹង ៤១,៣១%។ ដោយឡែកនៅទីប្រជុំជនក្រុងច្បារមន ប្រជាពលរដ្ឋមានទឹកស្អាតប្រើប្រាស់ចំនួន ១២.៣៧១គ្រួសារ ស្មើនឹង ៩០,០២%។

ក្រុមហ៊ុនផ្គត់ផ្គង់និងចែកចាយអគ្គិសនី (រដ្ឋនិងឯកជន)ចំនួន ២១ក្រុមហ៊ុនបានភ្ជាប់ បណ្តាញអគ្គិសនីចូលដល់ភូមិចំនួន ១.៣៦៧ភូមិ ស្មើនឹង៩៩,១៣% ប្រជាពលរដ្ឋមានអគ្គិសនីប្រើប្រាស់ចំនួន ១៨៨.៥២៨ ស្មើនឹង៩២,២១%។

## ២-ការងារសុខាភិបាល

ប្រជាពលរដ្ឋ ដែលបានមកទទួលការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ ដើម្បីបង្កើនភាពស៊ាំក្នុងសហគមន៍ដូចខាងក្រោម ៖

ប្រជាជនក្នុងខេត្តទទួលបានការចាក់វ៉ាក់សាំងបង្ការជំងឺកូវីដ-១៩ លទ្ធផលទទួលបានដូចខាងក្រោម៖

- ប្រជាជន និងកុមារចាប់ពីអាយុ ០៥ឆ្នាំឡើង បានទទួលចាក់ដូសមូលដ្ឋានមានចំនួនសរុប ៧៩៧.១៩៥នាក់ ស្មើនឹង ៩៧,៦២% នៃប្រជាជនសរុប ៨១៦.៦០៣នាក់។ កុមារចាប់ពីអាយុ ០៣ ឆ្នាំដល់ក្រោម ០៤ ឆ្នាំ បានទទួលចាក់ដូសមូលដ្ឋានមានចំនួនសរុប ១៩.៤៤៨នាក់ ស្មើនឹង៥៨,៥៩% នៃកុមារសរុប ៣៣.១៩២ នាក់។
- ការចាក់ដូសជំរុញទី ៣ សរុបៈ ៤៣៥.៧០១ នាក់ ស្មើនឹង ៦៦,៤២%
- ការចាក់ដូសជំរុញទី ៤ សរុបៈ ១៦១.៤៨០ នាក់ ស្មើនឹង ៣៧,០៦%
- ការចាក់ដូសជំរុញទី ៥ សរុបៈ ២៨.២១១ នាក់ ស្មើនឹង ១៧,៤៧%
- ការចាក់ដូសជំរុញទី ៦ សរុបៈ ១.៥៣០ នាក់ ស្មើនឹង ៥,៤២%

ភាពជោគជ័យនៃការចាក់វ៉ាក់សាំងនេះ អាស្រ័យដោយមានការដឹកនាំផ្ទាល់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។**

## ៣-កម្មវិធីជំនួយសង្គមរបស់រាជរដ្ឋាភិបាល

ការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងកំឡុងពេលប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ រួមមានៈ

- គ្រួសារមកផ្ទៀងផ្ទាត់ឈ្មោះបើកប្រាក់ គិតចាប់ពីថ្ងៃអនុវត្តរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ សរុបមានចំនួន ៣៧.៩៣៥គ្រួសារ។
- គ្រួសារមកទទួលការឧបត្ថម្ភជុំបន្ទាប់គិតចាប់ពីថ្ងៃចាប់ផ្តើមរហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ ចំនួន ៣.៧២៣គ្រួសារ។
- ចំណាយថវិកាគិតចាប់ពីថ្ងៃអនុវត្ត ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ សរុបមានចំនួន ១៣០.៧៥៤.៨៧៦.០០០រៀល។

## ៤-ការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ

សភាពការណ៍សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ក្នុងភូមិសាស្ត្រខេត្តមានលក្ខណៈល្អប្រសើរនេះ ជាលទ្ធផលស្តែងចេញពីមនសិការការងារ និងវិជ្ជាជីវៈ ការខិតខំប្រឹងប្រែងតស៊ូរបស់មន្ត្រីរាជការកងកម្លាំងប្រដាប់អាវុធគ្រប់ផ្នែក និងគ្រប់លំដាប់ថ្នាក់ទាំងអស់ក្នុងខេត្ត។ បទល្មើសជាទូទៅត្រូវបានបង្ក្រាបជាបន្តបន្ទាប់ សន្តិសុខសណ្តាប់ធ្នាប់ត្រូវបានធានា និងពង្រឹង។ ជាក់ស្តែងបានបង្ក្រាបបទល្មើសព្រហ្មទណ្ឌនៅទូទាំងខេត្តចំនួន ២៥២ករណី ស្មើនឹង ៩៨%។

- បានចាត់តាំងអនុវត្តន៍ចលនាប្រជាការពារនៅគ្រប់ឃុំ សង្កាត់ កម្លាំងប្រជាការពារចំនួន ១២.៩៩២ នាក់។

- បានចុះផ្សព្វផ្សាយគោលនយោបាយ "**ភូមិ.ឃុំ.សង្កាត់មានសុវត្ថិភាព**" និងច្បាប់ផ្សេងៗ ១៧.១១៣លើក ប្រជាពលរដ្ឋចូលរួមសរុបចំនួន ៨០៤.៧៥០នាក់។

## ៥-ការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-ផែនការបង្កបង្កើនផលស្រូវរដូវប្រាំងរយៈពេល ៥ឆ្នាំ (២០១៨-២០២២) ចំនួន ៣.១៤០ហ.ត ដោយអនុវត្ត និងប្រមូលផលបានចំនួន ២.៤៩៨ហ.ត ស្មើនឹង ៧៩,៥៥%។ ទិន្នផលជាមធ្យមទទួលបាន

៣,៣៨២តោន/ហ.ត គិតជាបរិមាណផលសរុបចំនួន ៨.៣៣៩តោន និងដំណាំរួមផ្សំអនុវត្តបានចំនួន ២.១៨២ហ.ត។

-ផែនការបង្កបង្កើនផលស្រូវរដូវវស្សារយៈពេល ៥ឆ្នាំ (២០១៨-២០២២) មានផ្ទៃដីចំនួន ៥៦៨.០០០ហ.ត ដោយអនុវត្តបានសរុបចំនួន ៥៩៣.២១១ហ.ត ។ផ្ទៃដីប្រមូលផលបានក្នុងឆ្នាំ (២០១៨-២០២២) ចំនួន ៥៨៩.២៧៧ហ.ត ស្មើនឹង៩៩,៣៣% ផ្ទៃដីខូចខាតទាំងស្រុងចំនួន ៣.៩៣៤ហ.ត ។ ទិន្នផលជាមធ្យមទទួលបាន ៣,១៩៥តោន/ហ.ត គិតជាបរិមាណផលសរុបទទួលបានចំនួន ១.៨៨៥.៤៣៧តោន និងដំណាំរួមផ្សំអនុវត្តបានចំនួន ១៣.៧៦៤ ហ.ត។

-តុល្យភាពស្បៀងសម្រាប់រយៈពេល ៥ឆ្នាំ (២០១៨-២០២២) បរិមាណផលសរុបចំនួន ១.៨៩៣.៧៧៦តោន ទុកពូជ និងបាត់បង់ពេលប្រមូលផលចំនួន ២៤៦.១៩១តោន ស្មើនឹង១៣% តុល្យភាពស្បៀងគិតជាអង្ករ ៤១៩.៤៧០តោន និងតុល្យភាពស្បៀងគិតជាស្រូវ ៦៥៥.១០៩តោន ។

- ការងារសម្បទានដីសេដ្ឋកិច្ច មានក្រុមហ៊ុនវិនិយោគលើសម្បទានដីសេដ្ឋកិច្ចចំនួន ១៩ក្រុមហ៊ុន ក្នុងនោះក្រុមហ៊ុនដែលបានចុះបញ្ជី ១០ក្រុមហ៊ុន ដាក់ពាក្យស្នើសុំចុះបញ្ជីចំនួន ៦ក្រុមហ៊ុន ចេញប័ណ្ណចំនួន ១០ក្រុមហ៊ុន និងត្រៀមបោះបង្គោលព្រំចំនួន ៦ក្រុមហ៊ុន ដែលមានផ្ទៃដីវិនិយោគសរុបចំនួន ១០២.២០៧ហ.ត ក្នុងនោះបានឈូសឆាយចំនួន ៦៥.៤៩៤,៦៤ហ.ត ផ្ទៃដីដាំដុះសរុបចំនួន ៣៦.៩៦៣,០៩ហ.ត ក្នុងនោះមាន អំពៅចំនួន២២.២១២,២៥ហ.ត ស្វាយចំនួន ២.០៩៨ហ.ត កៅស៊ូចំនួន ២៣៤ហ.ត ម៉េសាក់ចំនួន ៤.៦៧៦,៤៧ហ.ត អាកាស្យាចំនួន ៤៣០,៩៨ហ.ត ស្វាយចន្ទីរចំនួន ១៨៨,៨៥ហ.ត ស្មៅ+ចេក ចំនួន ៣១៣,០៧ហ.ត ប្រេងខ្យល់ចំនួន ១.៣១៨,៨៦ហ.ត ស្រូវចំនួន ២០ហ.ត ដូងចំនួន ១០ហ.ត ល្មើចំនួន ១០ហ.ត ដំឡូងមី ៥.៣៦៥ហ.ត និងដំណាំរួមផ្សំ ៣៨,៤៨ហ.ត។

រោងចក្រកែច្នៃផលិតផលកសិកម្មចំនួន ១៣កន្លែង ក្នុងនោះ រោងចក្រកែច្នៃអំពៅ (ស្ករស)ចំនួន ០១កន្លែង រោងចក្រកែច្នៃដំឡូងមី ០១កន្លែង និងរោងចក្រដំណាប់ស្វាយ ១១កន្លែង ស្រូបយកកម្លាំងពលកម្មបានចំនួន ៤.៤២៤នាក់ ទទួលបានប្រាក់ចំណូលប្រមាណ ២០.១៨៤.៥០០ដុល្លាក្នុងមួយឆ្នាំ។

## ៦-ការងារឧស្សាហកម្ម

បច្ចុប្បន្ន ទូទាំងខេត្តកំពង់ស្ពឺមានរោងចក្រ សហគ្រាស គ្រឹះស្ថានចំនួន ៣៨៣ កន្លែង មានកម្មករនិយោជិតសរុបចំនួន ១៥៥.៧៦១នាក់ ស្រី ១១៥.៥២២នាក់។ ក្នុងនោះវិស័យវាយនភ័ណ្ឌកាត់ដេរសម្លៀកបំពាក់ និងស្បែកជើងចំនួន ១៨៩កន្លែង មានកម្មករនិយោជិតសរុប ១៤៥.៣៩៩នាក់ ស្រី ១១០.៨៤៣នាក់។ ជាមួយគ្នានេះ ក៏មានរោងចក្រធុនធំចំនួន ២២៩មូលដ្ឋាន ប្រើប្រាស់កម្លាំងពលកម្មសរុបចំនួន ១៣២.៥០៣ នាក់ ស្រី ១០២.៨៨៥នាក់ ដោយប្រើប្រាស់ទុនវិនិយោគសរុប ១.៧១៤.៨៣៦.០០០ ដុល្លាសហរដ្ឋ អាមេរិក។ រោងចក្រធុនតូចនិងមធ្យម និងសិប្បកម្មមានចំនួន ១.១៣០មូលដ្ឋាន ទុនវិនិយោគចំនួន ២៦.៤៤៩.៩១០ដុល្លា ប្រើប្រាស់កម្លាំងពលកម្មសរុបចំនួន ១៤.៦២០នាក់ ស្រីចំនួន ៧.៧០០នាក់។

## ៧-ការងាររ៉ែ និងថាមពល

ទូទាំងខេត្តកំពង់ស្ពឺ មានអាជីវកម្មធនធានរ៉ែសរុបចំនួន ២៥៦ការដ្ឋាន ក្នុងនោះដំណើរការ ១៥៧ការដ្ឋាន រួមមានការដ្ឋានថ្មសំណង់៣៣ការដ្ឋាន ថ្មអារ១៣ការដ្ឋាន ខ្សាច់ស្ទឹង៧ការដ្ឋាន ខ្សាច់បក៤ការដ្ឋាន ដីករណ្តៅដី៣ការដ្ឋាន សិប្បកម្មថ្មបំបែកចំនួន៣ការដ្ឋាន អាជ្ញាប័ណ្ណសិប្បកម្មខ្សាច់បក៨ការដ្ឋាន អាជ្ញាប័ណ្ណសិប្បកម្មដីករណ្តៅដី៧ការដ្ឋាន អាជ្ញាប័ណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មដីកអាចម៍ដី រណ្តៅដីចល័ត

ចំនួន ៥៦អាជ្ញាប័ណ្ណ ការដ្ឋានស្តាទំនប់ទឹកចំនួន២០ការដ្ឋាន និងគម្រោងកសាងហេដ្ឋារចនាសម្ព័ន្ធចំនួន ២ការដ្ឋាន។

**៨-ការងារទេសចរណ៍**

ក្នុងរយៈពេល ៥ឆ្នាំ មានភ្ញៀវទេសចរណ៍ចូលទស្សនាតាមរមណីយដ្ឋាននានា និងស្នាក់នៅក្នុងខេត្ត មានចំនួន ១.៤២០.២៦៦នាក់ រួមមាន ភ្ញៀវទេសចរណ៍ជាតិចំនួន ១.៣៧០.១៨១នាក់ និងភ្ញៀវអន្តរជាតិ ៥០.០៨៥នាក់។

រមណីយដ្ឋាននិងសហគមន៍ទេសចរណ៍សរុបចំនួន ២៥ ទីតាំង ក្នុងនោះ រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ ០៤ កន្លែង រមណីយដ្ឋានធម្មជាតិកែច្នៃ ០៥ កន្លែង រមណីយដ្ឋានកសិ-ទេសចរណ៍ ០៣កន្លែង សហគមន៍ ០៨ កន្លែង និងគោលដៅទេសចរណ៍ថ្មីៗ ០៥ កន្លែង។ ទូទាំងខេត្ត មានសណ្ឋាគារ៦កន្លែង ស្មើនឹង២០៦បន្ទប់ ផ្ទះសំណាក់៣០កន្លែង ស្មើនឹង៣៧១បន្ទប់ ភោជនីយដ្ឋាននិងអាហារដ្ឋាន១២៩កន្លែង ឌីស្កូតែក(ក្លឹប)០១កន្លែង បៀហ្គាឌិន២កន្លែង ខារ៉ាអូខេ៣៨កន្លែង និងម៉ាស្សា២កន្លែង។

**៩-ការងារអប់រំ យុវជន និងកីឡា**

សាលាមត្តេយ្យសិក្សាសាធាណៈនិងចំណេះទូទៅសាធារណៈ និងឯកជនមានចំនួន ៦៩៥កន្លែង បឋមសិក្សាចំនួន ៣១៦ កន្លែង អនុវិទ្យាល័យចំនួន ៧២ កន្លែង វិទ្យាល័យចំនួន ២៥ កន្លែង ថ្នាក់សមមូលបឋម ៤០ ថ្នាក់ និងសាលាឯកជនមានចំនួន ៨៣ កន្លែង។ ក្នុងនោះអគារសិក្សាដែលជាអំណោយដ៏ថ្លៃថ្លារបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជាមានចំនួន ១៨៧ ខ្នង ស្មើនឹង១.០៣៦បន្ទប់។ សិស្សសរុប ១៧៣.៤៨៤នាក់/ស្រី ៨៥.៥៥៥ នាក់។

គ្រឹះស្ថានឧត្តមសិក្សានិងវិទ្យាស្ថានមានចំនួន ៤កន្លែង មាននិស្សិតកំពុងសិក្សាចំនួន ២.៣៤៥នាក់ ស្រី១.៣៩៤ នាក់។

រយៈពេល៥ឆ្នាំកន្លងមក លទ្ធផលប្រកួតកីឡាជើងឯកថ្នាក់ជាតិ យើងទទួលបានមេដាយសរុបចំនួន ៥៦ ក្នុងនោះមេដាយមាស ១៥ ប្រាក់ ២៤ និងសំរិទ្ធ១៧។

រយៈពេល ៥ឆ្នាំ មានបេក្ខជនប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ចំនួន ២២.៤៣៩នាក់ ស្រី ១១.៦៨៣នាក់ ក្នុងនោះបេក្ខជនប្រឡងជាប់ចំនួន១៨.០៩៥នាក់ ស្រី៩.៨៧៧នាក់ បេក្ខជនទទួលបាននិទ្ទេស **A** ចំនួន៦៨នាក់ ស្រី៤៦នាក់ និទ្ទេស **B** ចំនួន៥១៤នាក់ ស្រី២៨៦នាក់ និទ្ទេស **C** ចំនួន១.៦៣៣នាក់ ស្រី១.០២៦នាក់ និទ្ទេស **D** ចំនួន៣.៥១៨នាក់ ស្រី២.០៩២នាក់ និទ្ទេស **E** ចំនួន៧.៦៣៥ នាក់ ស្រី ៣.៨៩០នាក់។

**១១-ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី**

ការងារចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធគិតពីឆ្នាំ២០១៨ ដល់ត្រីមាសទី១ឆ្នាំ២០២៣ បានបញ្ចូលទិន្នន័យក្បាលដីសម្រេចបានចំនួន ១៣១.៦៥៩ក្បាលដី កំពុងបិទផ្សាយជាសាធារណៈចំនួន ១១៤.០៩៥ ក្បាលដី និងបានចែកប័ណ្ណជូនប្រជាពលរដ្ឋចំនួន ៨២.៥០៣ ប័ណ្ណ ។ក្នុងនោះដីរដ្ឋដែលបានចុះបញ្ជីលក្ខណៈជាប្រព័ន្ធ មានចំនួន ១.៣៦៨ក្បាលដី ( បានចេញបណ្ណចំនួន ១.៣៥២ក្បាលដី, កំពុងដំណើរការចុះបញ្ជីចំនួន ១៦ក្បាលដី )

ការងារចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំសម្រេចបានចំនួន១.៥២១ក្បាលដី ការចុះបញ្ជីដីរដ្ឋសម្រេចបានចំនួន៩៨ក្បាលដី ការចុះបញ្ជីសិទ្ធិជួលអចិន្ត្រៃយ៍បានចំនួន០៣ក្បាលដី ការចេញលិខិតអនុញ្ញាតសាងសង់ចំនួន១០១ក្បាលដី ការអភិវឌ្ឍដីចំនួន៧៥គម្រោង។

**១២-ការងារសាធារណការ និងដឹកជញ្ជូន**

ការថែទាំ និងស្តារបនាផ្លូវរយៈពេល ៥ឆ្នាំ (២០១៨-២០២២) រួមមាន ៖ ផ្លូវកៅស៊ូប្រវែង ៤៥,១៤គ.ម, ផ្លូវបេតុងប្រវែង១០០ម, ផ្លូវក្រាលគ្រួសក្រហមប្រវែង ២៩,៩០គ.ម, សាងសង់លូមូលបណ្តោយផ្លូវ ២.៩០០ម, ជួសជុលលូមូលបណ្តោយផ្លូវ ៨៣២ម, សាងសង់ស្ពានបេតុង ៣៦ម, សាងសង់លូប្រអប់ទទឹងផ្លូវ ៧៦ម, សាងសង់លូមូលទទឹងផ្លូវ ៤១១ម, ការថែទាំជាប្រចាំផ្លូវជាតិនិងផ្លូវខេត្តក្រាលកៅស៊ូ ១.៥៣៧,៣៦គ.ម និង ការថែទាំប្រចាំផ្លូវជាតិ និងផ្លូវខេត្តក្រាលដីល្បាយថ្ម ១.៣៣២,៦២គ.ម។

ក្រៅពីផ្លូវជាតិនិងផ្លូវខេត្ត យើងនូវមានផ្លូវល្បឿនលឿនមួយខ្សែទៀត ដែលទើបនឹងសាងសង់រួចដោយឆ្លងកាត់ខេត្តកំពង់ស្ពឺប្រវែង ៨០,៨០គ.ម ដែលសាងសង់ដោយក្រុមហ៊ុន **PPSHV Expressway Co.,Ltd** ដែលបានសម្ពោធជានិមិត្តរូបដាក់ឱ្យប្រើប្រាស់ជាផ្លូវការផ្លូវល្បឿនលឿនភ្នំពេញ-ក្រុងព្រះសីហនុ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងឯកឧត្តម លី ខឺឈាំង (**Li Keqiang**) នាយករដ្ឋមន្ត្រី នៃសាធារណរដ្ឋប្រជាមានិតចិន អមដោយវត្តមានថ្នាក់ដឹកនាំជាន់ខ្ពស់នៃប្រទេសទាំងពីរ **កម្ពុជា-ចិន**។

ការងារដឹកជញ្ជូន បានចុះបញ្ជីយានយន្ត ៤៧.២៧១គ្រឿង, ត្រួតពិនិត្យបច្ចេកទេស(ឆៀក) ៦៩.៥៤៩ គ្រឿង, លិខិតអនុញ្ញាធ្វើអាជីវកម្មដឹកជញ្ជូន ២៤.៧៨៣គ្រឿង និងប្រឡង និងផ្តល់បណ្ណបើកបរ ១០.៣៦៦ នាក់។

**១៣-ការងារធនធានទឹក និងឧតុនិយម**

បានជួសជុលទំនប់ចំនួន៨៤កន្លែង ប្រវែង១០៧.២៩២ម៉ែត្រ, ស្តារប្រឡាយមេចំនួន២៣ខ្សែ ប្រវែង ៨៧.០២០ ម៉ែត្រ, ស្តារប្រឡាយរងបានចំនួន ៣១ខ្សែ ប្រវែង ៤១.៣៤៦ ម៉ែត្រ, ស្តារប្រឡាយជើងក្អែប បានចំនួន ៣៣៦ខ្សែ ប្រវែង ២៦៥.៧៨៩ ម៉ែត្រ។

បានជួសជុលសំណង់សិល្បៈការបានចំនួន ១១១កន្លែង រួមមាន ទ្វារទឹកចំនួន៥៧កន្លែង លូទឹកចំនួន ៣៥កន្លែង សំណង់ស្នាក់ទឹកចំនួន ១០កន្លែង សំណង់បង្ហៀរចំនួន ០៨កន្លែង និងស្ពាន ០១កន្លែង ។

តាមរយៈសមិទ្ធផល ដែលសម្រេចបានក្នុងរយៈពេល៥ឆ្នាំ (២០១៨-២០២២)កន្លងមកនេះ យើងទាំងអស់គ្នា មិនអាចបំភ្លេចបានទេ នូវតម្លៃនៃសន្តិភាព ហើយតម្លៃសន្តិភាពគឺមិនអាចកាត់ថ្លៃបានឡើយ។

**១៤.ទិសដៅបន្ត**

រដ្ឋបាលខេត្តកំពង់ស្ពឺ នឹងបន្តយកចិត្តទុកដាក់ខិតខំអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនស្របតាមទិសដៅរបស់ខេត្តដែលបានដាក់ចុះ និងទិសដៅរបស់ក្រសួងមហាផ្ទៃឱ្យសម្រេចបានលទ្ធផលជាផ្លែផ្កាលើគ្រប់វិស័យ ធានាបាននូវសន្តិសុខសណ្តាប់ធ្នាប់សាធារណៈជូនប្រជាពលរដ្ឋ។ ការអភិវឌ្ឍ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធនានារបស់ខេត្ត ដើម្បីលើកកម្ពស់សេដ្ឋកិច្ច និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ជាពិសេសអភិវឌ្ឍវិស័យសំខាន់ៗដូចជាវិស័យកសិកម្ម វិស័យធនធានទឹក ប្រព័ន្ធធារាសាស្ត្រដែលបានជំរុញផលិតកម្មកសិកម្មទទួលបានផលជាអតិបរិមា និងការផ្តល់ឱកាសការងារជូនប្រជាពលរដ្ឋតាមរយៈការវិនិយោគលើវិស័យ

វាយណភ័ណ្ឌដែលបានធ្វើឱ្យអត្រានៃភាពក្រីក្រថយចុះគួឱ្យកត់សំគាល់។ ទន្ទឹមនេះ វិស័យសង្គមកិច្ចក៏ត្រូវបានយកចិត្តទុកដាក់ និងកែលម្អជាបន្តបន្ទាប់ដើម្បីលើកកម្ពស់សុខុមាលភាព និងគុណភាពជីវិត របស់ប្រជាពលរដ្ឋតាមរយៈការជំរុញវិស័យសុខាភិបាល និងវិស័យពាក់ព័ន្ធនានា ព្រមទាំងជំរុញយ៉ាងសកម្មនូវការកែទម្រង់អភិបាលកិច្ច ការអភិវឌ្ឍសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ ការពង្រឹងការផ្តល់សេវាសាធារណៈគ្រប់ប្រភេទ និងការកែលម្អសោភ័ណ្ឌភាពទីប្រជុំជនទីក្រុង បង្កលក្ខណៈសប្បាយរីករាយដល់ប្រជាពលរដ្ឋ។

ជាថ្មីម្តងទៀត ក្នុងនាមក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធ និងប្រជាពលរដ្ឋខេត្តកំពង់ស្ពឺ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ **ខ្ញុំសូមអរគុណសន្តិភាព! មានសន្តិភាពមានការអភិវឌ្ឍ មានការអភិវឌ្ឍទើបធ្វើឱ្យប្រទេសជាតិ យើងមានការរីកចម្រើនដូចសព្វថ្ងៃ។ ដូចនេះ យើងទាំងអស់គ្នាត្រូវតែចូលរួមថែរក្សាការពារសន្តិភាពរបស់ ប្រទេសជាតិយើងឱ្យស្ថិតនៅគង់វង្សជាអមតៈតរៀងទៅ។**

ពាក្យស្លោក "**អរគុណសន្តិភាព អរគុណនយោបាយ ឈ្នះ ឈ្នះ**" បានលាន់រន្ទឺពាសពេញប្រទេស និងបានក្លាយជាស្មារតីនៃការរួបរួមរបស់សង្គមជាតិដ៏ខ្លាំងក្លា រស់រវើកនៅក្នុងដំណើរការកសាង ការពារមាតុភូមិ និងអភិវឌ្ឍន៍ឥតឈប់ឈរ។ បើយើងរក្សាសន្តិភាពមិនបាន យើងពិតជាមិនអាចទទួលបាននូវសមិទ្ធផល គ្រប់យ៉ាងដូចសព្វថ្ងៃនេះបានឡើយ។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យមហាប្រសើរថ្លៃថ្លាជូនចំពោះ សម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានបានទស្សនាការផ្សាយផ្ទាល់ និងវត្តមានរបស់ឯកឧត្តម លោកជំទាវ លោក លោកស្រី បងប្អូនអ្នកសារព័ត៌មានទាំងអស់ដែលមានវត្តមាននៅក្នុងសន្និសីទសារព័ត៌មាននេះ សូមបានប្រកបនូវ ពុទ្ធពរទាំង **បួន** ប្រការ **អាយុ វណ្ណៈ សុខៈ និងពលៈ** កុំបីឃ្លៀងឃ្លាតឡើយ៕

**សូមអរគុណ**...!